ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

*ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០២៥*

## កម្មវិធី Taste of Australia 2025 - ការបង្ហាញអំពីផលិតផលអូស្ត្រាលីកម្រិតពិភពលោក

ស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានរៀបចំកម្មវិធី Taste of Australia 2025 ប្រកបដោយមោទនភាព ដោយព្រឹត្តិការណ៍នេះ មានគោលបំណងដាក់បង្ហាញនូវគ្រឿងអាហារគុណភាពខ្ពស់ និងស្រាដ៏ប្រណីតរបស់ប្រទេសអូស្ត្រាលី ល្បីល្បាញឈានមុខកម្រិតពិភពលោក។

កម្មវិធីនេះបានប្រព្រឹត្តិទៅនៅរាជធានីភ្នំពេញ ដោយមានការពីសំណាក់ភ្ញៀវកិត្តិយសរួមមាន មន្ត្រីរាជ-រដ្ឋាភិបាលជាន់ខ្ពស់ ធុរកិច្ចជនជាន់ខ្ពស់ តំណាងសារព័ត៌មាននិង ប្រព័ន្ធផ្សព្វផ្សាយ រួមជាមួយនិងអ្នកបង្កើតមាតិកាល្បីៗនៅក្នុងវិស័យម្ហូបអាហាររបស់កម្ពុជា។

ភ្ញៀវកិត្តិយសបានរីករាយជាមួយបញ្ជីមុខម្ហូបពិសេស ដែលរួមបញ្ចូលនូវគ្រឿងផ្សំដែលបានជ្រើសរើសយ៉ាងសម្រិតសម្រាំង រួមមានសាច់គោវ៉ាគ្យូ (Wagyu) មកពីរដ្ឋអូស្ត្រាលីខាងត្បូង (South Australia) សាច់គោធម្មជាតិដាលីងដោនស៍ (Darling Downs) របស់រដ្ឋឃ្វីនឡេនដ៍ (Queensland) ខ្យងសមុទ្រខៀវ និងមឹកពីរដ្ឋអូស្ត្រាលីភាគខាងលិច (Western Australia) និងញ៉ូវសៅវ៉ែល (New South Wales) រួមទាំងសាច់ជ្រូកផ្អែមបានហ្គាឡូ (Bangalow) ពីបៃរ៉ន បេយ៍ (Byron Bay)។ ម្ហូបទាំងនេះ ត្រូវបានផ្សំគ្នាជាមួយស្រាពិសេស រួមមាន Riesling, Chardonnay, Shiraz និង Cabernet shiraz នៅក្នុងបញ្ជីស្រារបស់ Penfolds សុទ្ធសឹងតែជាស្រាល្បីៗឈានមុខរបស់ប្រទេសអូស្ត្រាលី។

ឯកឧត្តម ដេរិក ឃើប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា "*កម្មវិធី Taste of Australia គឺជាកម្មវិធីអបអរ និងបង្ហាញនូវផលិតផលល្អបំផុតមួយចំនួនរបស់អូស្ត្រាលី ដែលយើងមានសម្រាប់ផ្តល់ជូនពិភពលោក មានប្រភពចេញពីកសិដ្ឋានធម្មជាតិនៃស្មួនបៃតង ទឹកថ្លាបរិសុទ្ធ និងចំការទំពាំងបាយជូររបស់អូស្ត្រាលី ដាក់ជូនជាអាហារនៅរាជធានីភ្នំពេញ"។*

*"អូស្ត្រាលីមានឈ្មោះល្បីល្បាញជាសកលក្នុងការផលិតអាហារដែលមានអនាម័យ បៃតង និងប្រកបដោយចីរភាព ហើយយើងមានមោទនភាពក្នុងការនាំយកអាហារទាំងនេះមកចែករំលែកដល់មិត្តភក្តិកម្ពុជារបស់យើងបានភ្លក់រសជាតិក្នុងថ្ងៃនេះ" ។*

*"ផលិតផលទាំងអស់ដែលយើងបានដាក់បង្ហាញក្នុងថ្ងៃនេះ គឺសុទ្ធតែអាចរកបាននៅទីនេះ ក្នុងប្រទេសកម្ពុជា រួមជាមួយនឹងផលិតផលដ៏អស្ចារ្យផ្សេងៗទៀតរបស់អូស្ត្រាលីផងដែរ" ។*

កម្មវិធី Taste of Australia 2025 គឺជាផ្នែកមួយនៃយុទ្ធនាការក្នុងតំបន់ ក្នុងគោលបំណងលើកកម្ពស់ការនាំចេញគ្រឿងអាហារ និងភេសជ្ជៈរបស់អូស្ត្រាលី និងដើម្បីពង្រឹងភាពជាដៃគូផ្នែកវប្បធម៌ សេដ្ឋកិច្ច និងការទូត នៅទូទាំងអាស៊ីអាគ្នេយ៍ តាមរយៈសិល្បៈនៃម្ហូបអាហារ។

**ទំនាក់ទំនងព័ត៌មាន :** Media.Cambodia@dfat.gov.au